រក្សាសិទ្ធិ © ពត៌មាន :
© ២០០៩ Project WorldReach © ២០០៩ SEAN
រក្សាសិទ្ធិគ្រប់យ៉ាង

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

Project WorldReach (T&M™ ព័ន្ធកិច្ចប្រតិបត្តិការ)
Dr. George Patterson, (អ្នកនិពន្ធកម្មវិធី)
SEAN អន្តរជាតិ

អាស័យដ្ឋានសំរាប់ទាក់ទង :
Project WorldReach PWR ™
474 - 800 - 15355 - 24th Ave
Surrey BC, Canada
V4A 2H9

E-mail: pwr@trainandmultiply.com
Website: http://www.trainandmultiply.com

021KH01A-01

អ្នកជិតខាងរបស់ខ្ញុំ



កូនស្បៃរំភៅសំរាប់បង្ហាត់បង្រៀនគ្រូគង្វាល

២១

បង្ហាត់បង្រៀន និង បង្កើនចំនួនបន្ត ®

T&M ™

សូមព្រះអម្ចាស់ប្រើមេរៀននេះ ដើម្បីជួយអោយកូនៗរបស់ព្រះអង្គ ចេះបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកជិតខាង មិនមែនត្រឹមតែ ដោយពាក្យសំដីប៉ុណ្ណោះទេ តែដោយអំពើដែលយើងប្រព្រឹត្ត ផងដែរ ។

បើគ្រាន់តែពោលថា ខ្លួនមានសេចក្តីស្រឡាញ់ ក៏ប៉ុន្តែ គ្មានធ្វើអ្វី បញ្ជាក់ពីសេចក្តីស្រឡាញ់នោះទេ គឺជាការមានពុតត្បុតហើយ : *«រូបកាយដែលគ្មានវិញ្ញាណ ជារូបកាយស្លាប់យ៉ាងណា ជំនឿ ដែលគ្មានការប្រព្រឹត្តអំពើល្អ ក៏ជាជំនឿស្លាប់យ៉ាងនោះដែរ »* ។

(យ៉ាកុប ២:២៦)

សាវ័កប៉ូលបង្រៀនពួកអ្នកស្រុកកាឡាទីអំពីជំនឿ ។ ជំនឿដែល មានចែងនៅក្នុងព្រះគម្ពីរសម្ពន្ធមេត្រីថ្មីនេះ បណ្តាលឱ្យមានការ ប្រព្រឹត្តអំពើល្អ ។ លោកប៉ូលបង្រៀនយើងតាមរយៈសំបុត្ររបស់ លោកថា÷

«យើងមិនត្រូវនឿយណាយនឹងប្រព្រឹត្តអំពើល្អឡើយ ដ្បិតប្រសិន បើយើងមិនបាក់ទឹកចិត្តទេនោះ ដល់ពេលកំណត់ យើងនឹងច្រូត បានផលជាមិនខាន ។ ហេតុនេះ ពេលយើងមានឱកាសនៅ ឡើយ យើងត្រូវប្រព្រឹត្តអំពើល្អចំពោះមនុស្សទាំងអស់ ជាពិសេស ចំពោះបងប្អូនរួមជំនឿ » ។ (កាឡាទី ៦:៩-១០)





© Project WorldReach © SEAN

កំណត់ចំណាំ :

តើអ្នកយល់ព្រមបង្ហាញសេចក្តីស្រឡាញ់របស់អ្នក ដោយការប្រព្រឹត្តអំពើល្អដែរឬទេ ? _____

អ្នកស្រុកសាម៉ារីដែលមានចិត្តសប្បុរស

ព្រះយេស៊ូបានប្រើប្រស្នាអំពីអ្នកស្រុកសាម៉ារី ដែលមានចិត្តសប្បុរស ដើម្បីធ្វើជាឧទាហរណ៍បំភ្លឺអំពីសេចក្តីស្រឡាញ់ ដោយការប្រព្រឹត្តអំពើល្អ ។



ឥឡូវនេះ សូមអានលូកា ១០:២៥-៣៧ ដោយពិនិត្យពិច័យ ។

☐ សូមគូសសញ្ញា «✓» នេះក្នុង «☐» ពេលដែលអ្នកបានអានរួចហើយ ។

តើជំបួង បណ្ឌិតខាងវិន័យទូលសួរព្រះយេស៊ូអំពីអ្វី ? (ខ ២៥)

ព្រះយេស៊ូសុំអោយបណ្ឌិតខាងវិន័យនោះ ឆ្លើយសំនួររបស់គាត់ដោយខ្លួនឯង ។ តើបណ្ឌិតខាងវិន័យនោះ ឆ្លើយតបដូចម្តេច ? (ខ ២៦-២៧) ។



កំណត់ចំណាំ :

© Project WorldReach © SEAN

កិច្ចការដែលត្រូវអនុវត្ត

- អធិស្ឋាន ទូលសូមឱ្យពួកអ្នកជឿបានចាក់ឫសយ៉ាងមាំមួន ក្នុងសេចក្តីស្រឡាញ់ (អេភេសូ ៣:១៧) ។
- ទន្ទេញ ១ យ៉ូហាន ៣:១៨ *«កូនចៅអើយ យើងមិនត្រូវស្រឡាញ់ត្រឹមតែបបូរមាត់ ឬពាក្យសំដីប៉ុណ្ណោះទេ គឺត្រូវស្រឡាញ់តាមអំពើដែលយើងប្រព្រឹត្ត និងតាមសេចក្តីពិតវិញ »* ។
- បង្រៀនរឿងអំពីអ្នកស្រុកសាម៉ារី ដែលមានចិត្តសប្បុរសដល់ក្រុមជំនុំរបស់អ្នក ។
- ជួយក្រុមជំនុំអោយចេះមើលឃើញថា សេចក្តីត្រូវការណា ដែលត្រូវដោះស្រាយរួមគ្នា ដោយសេចក្តីស្រឡាញ់ ។
- ជួយក្រុមជំនុំឱ្យអាចតែងតាំង និងណែនាំប្រមូលគ្រីស្តជន ដែលអាចចាត់ចែងការងារទាំងនេះ ។

តើចំលើយរបស់គាត់ត្រឹមត្រូវដែរឬទេ ?_____

សេចក្តីស្រឡាញ់ដោយការប្រព្រឹត្តអំពើល្អ កើតមានដោយសារជំនឿស្មោះត្រង់ ។ ព្រះវិញ្ញាណដ៏វិសុទ្ធគង់សណ្ឋិត និងធ្វើការក្នុងយើង តាមរយៈជំនឿរបស់យើង (កាឡាទី ៥:២២) ។

ទុតិយកថា ៦:៤-៥ : *«អ៊ីស្រាអែលអើយ ចូរស្តាប់ ! មានតែព្រះអម្ចាស់ ជាព្រះរបស់យើងមួយព្រះអង្គគត់ ដែលពិតជាព្រះ-អម្ចាស់ ។ អ្នកត្រូវស្រឡាញ់ព្រះអម្ចាស់ជាព្រះរបស់អ្នក អោយអស់ពីចិត្តគំនិត អស់ពីស្មារតី និងអស់ពីកម្លាំងកាយ »* ។

ដើម្បីអាចស្រឡាញ់ព្រះជាម្ចាស់ដូចនេះបាន យើងត្រូវទុកសេចក្តីបង្គាប់ទាំងឡាយរបស់ព្រះអង្គជាទីមួយជានិច្ច ។ យើងអាចស្រឡាញ់អ្នកជិតខាងរបស់យើងបាន ដោយសារតែយើងស្រឡាញ់ព្រះជាម្ចាស់ជាមុន ។ សេចក្តីស្រឡាញ់គ្រប់យ៉ាងមានប្រភពមកពីព្រះជាម្ចាស់ ព្រោះព្រះជាម្ចាស់ជាសេចក្តីស្រឡាញ់ ។ បណ្ឌិតខាងវិន័យក៏ទទួលស្គាល់សេចក្តីទាំងនេះដែរ ។ តែគាត់ចង់ជជែកវែកញែកអំពីសេចក្តីទាំងនេះ ។

តើគាត់ទូលសួរព្រះយេស៊ូដូចម្តេចនៅក្នុង លូកា ខ ២៩ ?

ព្រះយេស៊ូឆ្លើយតបនឹងសំនួរទីពីរនេះ ដោយនិយាយរឿងអំពីអ្នកស្រុកសាម៉ារីម្នាក់ ដែលមានចិត្តសប្បុរស ។

តើមានរឿងអ្វីកើតឡើងចំពោះជនជាតិយូដា ដែលធ្វើដំណើរពីទីក្រុងយេរូសាឡឹមទៅទីក្រុងយេរីខូ ?

តើបូជាចារ្យធ្វើដូចម្តេច នៅពេលទៅដល់កន្លែងកើតហេតុ ? (ខ ៣១)



ក្រុមជំនុំ/ ព្រះសហគមន៍បានតស៊ូ ដើម្បីធ្វើអោយកសិកម្ម និងឧស្សាហកម្មមានភាពប្រសើរឡើង នៅកន្លែងដែលបណ្តាជនជួបប្រទះនឹងការពិបាក ។

ពួកអ្នកជឿស្មោះត្រង់ តែងតែសំគាល់ឃើញសេចក្តីត្រូវការរបស់មនុស្ស ។ ពួកអ្នកជឿពិតតែងតែស្តាប់ ថែរក្សា ទៅសួរសុខទុក្ខ ផ្តល់យោបល់ និងជួយដល់មនុស្ស ។ បើសិនជាយើងបង្ហាញសេចក្តីស្រឡាញ់ ដោយការប្រព្រឹត្តអំពើល្អ សង្កាត់ទាំងមូលនឹងផ្លាស់ប្រែ ហើយរសជាតិអំបិលនឹងជ្រាបចូល ឯពន្លឺ នឹងបំភ្លឺគ្រប់ទីកន្លែង ។ ជួនកាល រដ្ឋាភិបាលជាច្រើន ព្រមទាំងរដ្ឋាភិបាលដែលមានសមាជិកមិនមែនជាគ្រីស្តជន សំរេចចិត្តគ្រប់គ្រងសង្គមតាមគោលការណ៍របស់អ្នកជឿលើព្រះគ្រីស្ត ។

ព្រះយេស៊ូដោះស្រាយបញ្ហារបស់សង្គម
តាមរយៈក្រុមជំនុំរបស់ព្រះអង្គ

ក្រុមជំនុំដែលសមាជិកបង្ហាញសេចក្តីស្រឡាញ់ ដោយការប្រព្រឹត្ត
អំពើល្អចំពោះអ្នកជិតខាងខ្លួន ជាពន្លឺសំរាប់សហគមន៍ទាំងមូល ។

ក្រុមជំនុំ/ ព្រះសហគមន៍បានតស៊ូប្រយុទ្ធ ដើម្បីរំដោះមនុស្សដែល
ត្រូវគេគាបសង្កត់ ឱ្យមានសេរីភាព ។ ក្រុមជំនុំ/ ព្រះសហគមន៍
គាំទ្រច្បាប់សំរាប់ការពារជនក្រីក្រ ។

ក្រុមជំនុំចាប់ផ្តើមសហគមន៍ដំបូង ដែលការពារកម្មករអោយទទួល
ប្រាក់ខែត្រឹមត្រូវ ។

ក្រៅពីធ្វើការផ្សាយដំណឹងល្អ និង បង្កើតក្រុមជំនុំ គ្រីស្តទូតបាន
គិតគូរពីសុខភាព និង ការអប់រំរបស់ពួកមនុស្សដែលសង្គមមិន
រាប់រក ។

ក្រុមជំនុំ/ ព្រះសហគមន៍ច្រើនតែផ្តត់ផ្តង់ថ្នាំសង្កូវដល់មនុស្សឈឺ
និងអ្នកក្រីក្រ ។ ក្រុមជំនុំ/ ព្រះសហគមន៍បានកសាងមណ្ឌល
សុខភាព និងមន្ទីរពេទ្យនៅក្នុងតំបន់ដែលខ្វះខាត ។

គ្រូគង្វាលអាចនិយាយថា÷ «ខ្ញុំរវល់ធ្វើកិច្ចការរបស់ព្រះជាម្ចាស់
ណាស់ គ្មានពេលដោះស្រាយបញ្ហាខាងរូបកាយអោយមនុស្ស
ដែលខ្ញុំមិនធ្លាប់ស្គាល់នោះទេ » ។ តែគ្រូគង្វាល ដែលគិតដូច
នេះ កំពុងធ្វើខុសដូចបូជាចារ្យនោះហើយ ។

តើបុរសលេវីធ្វើដូចម្តេច នៅពេលដើរមកដល់កន្លែងកើតហេតុ
នោះ ? (ខ ៣២)

_____

_____

មនុស្សខ្លះនិយាយថា÷« ការយកចិត្តទុកដាក់ជួយបំរើសេចក្តីត្រូវការ
របស់ក្រុមជំនុំសំខាន់ជាង ។ ហេតុអ្វីក៏យើងត្រូវទៅជួយមនុស្ស
ដែលយើងមិនធ្លាប់ស្គាល់សោះនោះ ?» ។ តែអ្នកដែលនិយាយ
ដូចនេះ ធ្វើខុសដូចបុរសលេវីនោះហើយ ។

តើអ្នកណាដែលមានចិត្តអាណិតអាសូរដល់ជនរងគ្រោះនោះ ?
(ខ ៣៣) _____

ពួកអ្នកស្រុកសាម៉ារីជាសត្រូវរបស់ពួកជនជាតិយូដា ។ ប៉ុន្តែ តើអ្នកស្រុកសាម៉ារីម្នាក់នេះ ធ្វើដូចម្តេច ចំពោះជនជាតិយូដា ដែលត្រូវរបួសនេះ ? សូមសរសេរអំពើបីយ៉ាង ដែលគាត់បានធ្វើ (ខ ៣៤-៣៥) ។ _____

_____

_____

ព្រះយេស៊ូសួរថា ក្នុងចំណោមមនុស្សទាំងបីនាក់នោះ តើអ្នកណាមួយ ជាអ្នកជិតខាងរបស់ជនរងគ្រោះ ដែលត្រូវចោរប្លន់ ? ។ តើអ្នកស្រុកសាម៉ារីនេះធ្វើអំពើអ្វី ដែលបង្ហាញពីសេចក្តីស្រឡាញ់របស់គាត់ ? (ខ ៣៦-៣៧)

_____

_____

_____

ឯទៀតវិញ ព្រះអង្គអោយពួកគេទៅឈរនៅខាងឆ្វេង ។ ពួកអ្នកទាំងនោះ នឹងធ្លាក់ទៅក្នុងបឹងភ្លើងអស់កល្ប (បឹងភ្លើងដែលឆេះមិនចេះរលត់) ។

មនុស្សដែលឈ្មើ ដើម្បីតែប្រយោជន៍ផ្ទាល់ខ្លួន

មានមនុស្សជាច្រើនដើរតាមព្រះយេស៊ូ ក្រោយដែលព្រះអង្គបានធ្វើការអស្ចារ្យ ប្រទាននំប៉័ង និងត្រីឱ្យមនុស្សប្រាំពាន់នាក់បរិភោគឆ្អែត ។ ព្រះយេស៊ូទតឃើញថា ពួកគេដើរតាមព្រះអង្គ ព្រោះតែចំណីអាហារប៉ុណ្ណោះ ។ ព្រះអង្គដាស់តឿនពួកគេ ដោយមានបន្ទូលប្រាប់ថា ចំណីអាហារតែមួយដែលផ្តល់ជីវិត គឺព្រះកាយរបស់ព្រះអង្គផ្ទាល់ ។ ពួកគេត្រូវទទួលស្គាល់ថា ព្រះអង្គបានធ្វើពលិកម្មដើម្បីពួកគេ ហើយពួកគេត្រូវថ្វាយជីវិតទៅព្រះអង្គ ដើម្បីអោយបានជីវិតអស់កល្ប ។ ប៉ុន្តែ ពួកគេមិនសប្បាយចិត្ត ហើយនាំគ្នាបែកចេញពីព្រះអង្គភ្លាម (យ៉ូហាន ៦) ។

មារសាតាំងតែងតែល្បួងអ្នកស្មោះត្រង់ អោយគិតតែពីប្រយោជន៍ផ្ទាល់ខ្លួន ។ របៀបការពារខ្លួនពីការល្បួងរបស់វានេះ គឺដាក់ជង្វាយស្ម័គ្រចិត្ត និងជង្វាយដប់ភាគរយដោយសប្បុរស និងបង្ហាញសេចក្តីស្រឡាញ់របស់យើង ដោយប្រព្រឹត្តអំពើល្អចំពោះមនុស្សឯទៀត ។

© Project WorldReach © SEAN

សេចក្តីស្រឡាញ់មានឥទ្ធិពល នៅថ្ងៃជំនុំជំរះដ៏គួរអោយកោតខ្លាច

ជំនឿពិតប្រាកដនាំអោយមានសេចក្តីស្រឡាញ់ ។ នៅពេលដែលព្រះជាម្ចាស់វិនិច្ឆ័យទោស ព្រះអង្គនឹងពិនិត្យមើលពីអំពើ ដែលមនុស្សលោកបានប្រព្រឹត្ត ។ អំពើល្អដែលពួកអ្នកជឿស្មោះត្រង់ធ្វើចំពោះមនុស្សឯទៀត ដោយសេចក្តីស្រឡាញ់ ជាភស្តុតាងបង្ហាញពីជំនឿពិតប្រាកដរបស់ពួកគេ ។ ព្រះយេស៊ូមានបន្ទូលប្រាប់ពីថ្ងៃជំនុំជំរះដ៏គួរឱ្យកោតខ្លាចនោះ នៅក្នុងម៉ាថាយ ២៥:៣១-៤៦ ។ ព្រះជាម្ចាស់នឹងជំនុំជំរះ ដោយចែកមនុស្សគ្រប់ជាតិសាសន៍ ជាចៀម និងពពែ ។ មនុស្សជាច្រើនហៅព្រះអង្គថា÷ «ព្រះអម្ចាស់» ប៉ុន្តែ ព្រះជាម្ចាស់មិនមែនសព្វព្រះហឫទ័យនឹងមនុស្សគ្រាន់តែដោយសារមនុស្សហៅព្រះអង្គថា÷ «ព្រះអម្ចាស់» ប៉ុណ្ណោះទេ ។ ព្រះអង្គសព្វព្រះហឫទ័យនឹងមនុស្ស ដែលហៅព្រះអង្គថា ព្រះអម្ចាស់ ហើយប្រព្រឹត្តអំពើល្អ ទុកជាភស្តុតាងអំពីជំនឿស្មោះត្រង់របស់ខ្លួន ។ ពួកអ្នកដែលប្រព្រឹត្តអំពើល្អចំពោះមនុស្សឯទៀត ដោយសេចក្តីស្រឡាញ់ ព្រះអង្គអោយពួកគេឈរខាងស្តាំ ។ ពួកអ្នកទាំងនោះ នឹងចូលទៅក្នុងសិរីរុងរឿងរបស់ព្រះអង្គ ។ រីឯពួកអ្នក ដែលមិនប្រព្រឹត្តអំពើល្អចំពោះមនុស្ស

រៀបចំគំរោងអធិប្បាយមួយអំពីលូកា ១០:២៥-៣៧ ។ បើសិនជាអ្នកមិនអាចធ្វើបាន ដោយខ្លួនឯង សូមប្រើគំរោងខាងក្រោមនេះ :

ប្រធានបទ : សេចក្តីស្រឡាញ់ ដោយការប្រព្រឹត្តអំពើល្អ។

បទគម្ពីរ : លូកា ១០:២៥-៣៧ ។

ចំណុច ទី ១ : សេចក្តីស្រឡាញ់ជាភស្តុតាងអំពីជំនឿស្មោះ-ត្រង់ (សូមអាន និងពន្យល់ ខ ២៥-២៩ ដោយបន្ថែមឧទាហរណ៍ផ្សេងៗទៀត) ។

ចំណុច ទី ២ : មិនអាចបង្ហាញថា មានសេចក្តីស្រឡាញ់ដោយគ្រាន់តែអធិប្បាយ ឬ ទៅព្រះវិហារនោះទេ ។ (សូមអាន និងពន្យល់ ខ ៣០-៣២ ដោយបន្ថែមឧទាហរណ៍) ។

ចំណុច ទី ៣ : យើងអាចបង្ហាញថា យើងមានសេចក្តីស្រឡាញ់របស់ព្រះគ្រីស្ត ដោយសារយើងប្រព្រឹត្តអំពើល្អចំពោះមនុស្សឯទៀត (សូមអាន និងពន្យល់ ខ ៣៣-៣៧ ដោយបន្ថែមឧទាហរណ៍) ។

© Project WorldReach © SEAN

ការអនុវត្ត : ក្នុងឋានៈជាគ្រីស្តជន យើងក៏ត្រូវជួយអ្នកជិតខាងរបស់យើង ពេលដែលគេត្រូវការដែរ ។ សេចក្តីស្រឡាញ់បែបនេះ ជាសក្ខីភាពអំពីជំនឿស្មោះត្រង់របស់យើង និង ជាសញ្ញាសំគាល់ថា យើងបានសង្គ្រោះហើយ ។ សូមពន្យល់សេចក្តីនេះ និង បន្ថែមឧទាហរណ៍ផ្សេងទៀត ។

មនុស្សមិនពេញលក្ខណៈ

ព្រះជាម្ចាស់បង្កើតយើងអោយមានសេចក្តីស្រឡាញ់ចំពោះព្រះអង្គ និងមនុស្សឯទៀតគ្រប់រូប ។ អ្នកដែលគ្មានសេចក្តីស្រឡាញ់ ជាមនុស្សមិនពេញលក្ខណៈ ។ គ្រីស្តជនម្នាក់ដែលអាត្មានិយម(គិតតែផលប្រយោជន៍ផ្ទាល់ខ្លួន) ប្រៀបដូចជាមនុស្សដែលមិនគ្រាន់តែខ្វះតែដៃមួយ ឬ ជើងមួយប៉ុណ្ណោះទេ តែខ្វះទាំងបេះដូងទៀតផង ។ បើមនុស្សម្នាក់គ្មានសេចក្តីស្រឡាញ់ ព្រលឹងរបស់អ្នកនោះនឹងក្រៀមស្វិត ហើយស្លាប់ជាមិនខាន ។



ដោយសារតែគ្មានសេចក្តីស្រឡាញ់ ទើបបានជាក្រុមជំនុំខ្លះមិនអាចរីកចំរើនបាន ។ ក្រុមជំនុំទាំងនោះមិនទទួលអ្នកជឿថ្មី ដោយសេចក្តីស្រឡាញ់ពិត និងដោយសន្ទុះចិត្តអបអរនោះទេ ។ ដោយសារព្រះជាម្ចាស់ទទួលអ្នកជឿថ្មីទាំងអស់ ក្រុមជំនុំក៏ត្រូវទទួលគេផងដែរ ។ បើសិនជាសមាជិកក្រុមជំនុំទទួលអ្នកជឿថ្មី ដោយសេចក្តីស្រឡាញ់ អ្នកនោះនឹងមានអារម្មណ៍ដឹងថា ព្រះជាម្ចាស់ស្រឡាញ់គាត់ដែរ ។ តែបើសិនជាសមាជិកក្រុមជំនុំមិនស្វះយកចិត្តទុកដាក់ចំពោះគាត់ គាត់នឹងពិបាកជឿណាស់ថា ព្រះជាម្ចាស់បានលើកលែងទោសអោយគាត់ ។